## រឿងទី៨៖ គេឌាន និងមនុស្សបីរយនាក់

**ខគម្ពីរ៖ ចៅហ្វាយ ៦៖១២**

ទេវតារបស់ព្រះអម្ចាស់មកបង្ហាញខ្លួនឲ្យលោកគេឌានឃើញ ហើយពោលថា៖ «វីរជនដ៏អង់អាចអើយ ព្រះអម្ចាស់គង់នៅជាមួយអ្នកហើយ»។

ជនជាតិអ៊ីស្រាអែលបាននាំគ្នាប្រព្រឹត្តអំពើបាបថ្វាយបង្គំរូបព្រះ ចំពោះព្រះជាម្ចាស់។
ព្រះជាម្ចាស់បានដាក់ទោសដល់ពួកជនជាតិអ៊ីស្រាអែល ទៅកណ្ដាប់ដៃពួកម៉ាឌាន។ ពួកសាសន៍ម៉ាឌានបានធ្វើទុក្ខបៀតបៀនដល់ជនជាតិអ៊ីស្រាអែលអស់រយៈពេល៧ឆ្នាំ។
ពេលជនជាតិអ៊ីស្រាអែល ដល់ពេលប្រមូលភោគផលពីស្រែចំការម្ដងៗ ពួកម៉ាឌាន តែងមកដណ្ដើមយកភោគផល ដែលប្រមូលបាននោះទៅអស់យ៉ាងច្រើន។
មិនត្រឹមតែប៉ុណ្ណោះ ពួកគេក៏យកគោ ចៀម លាពីជនជាតិអ៊ីស្រាអែលមកធ្វើដូចជារបស់ខ្លួន។
ជនជាតិអ៊ីស្រាអែលបានភ្ញាក់រលឹកដឹងថារឿងទាំងអស់នេះកើតឡើងដោយសារពួកគេបានប្រព្រឹត្តអំពើបាបចំពោះព្រះជាម្ចាស់
ដូច្នេះ ពួកគេក៏ចាប់ផ្ដើមទូលអង្វរដល់ព្រះជាម្ចាស់សុំឱ្យទ្រង់ជួយ។
ព្រះជាម្ចាស់បានស្ដាប់ការអធិស្ឋានរបស់ជនជាតិអ៊ីស្រាអែល និងបានជ្រើសរើសលោកគេឌាន
ប៉ុន្តែ គេឌានជាមនុស្សដែលកំសាក គាត់មិនស្ដាប់តាមការបង្គាប់របស់ព្រះជាម្ចាស់ទាំងស្រុងទេ ព្រោះគាត់ខ្លាច។
គេឌានបាននិយាយថា៖ «ប្រសិនបើព្រះអម្ចាស់ ពិតជាចង់សង្គ្រោះរាស្ត្រអ៊ីស្រាអែលតាមរយៈទូលបង្គំមែន នោះសូមបង្ហាញទីសម្គាល់មួយមក! ទូលបង្គំនឹងលាតស្បែកចៀម នៅលើលានបោកស្រូវ។ សូមទ្រង់ធ្វើឱ្យដីនៅស្ងួត ប៉ុន្តែស្បែកចៀមសើមវិញ»។
ព្រឹកឡើង គាត់បានទៅមើល គាត់មានការភ្ញាក់ផ្អើលជាខ្លាំង ព្រោះដីនៅស្ងួត ប៉ុន្តែស្បែកចៀមទទឹក។
ប៉ុន្តែ គេឌានមិនបញ្ឈប់ត្រឹមនេះទេ។ គេឌាន បានទូលសួរទៅព្រះជាម្ចាស់ម្ដងទៀត។
«ព្រះអម្ចាស់អើយ សូមបង្ហាញទីសម្គាល់ឱ្យទូលបង្គំឃើញម្ដងទៀតមក។ លើកនេះ សុំប្ដូរពីស្បែកចៀមសើម ទៅជាដី សើមវិញ»។
ព្រឹកថ្ងៃបន្ទាប់ ស្បែកចៀមក៏មានសភាពដូចដែលគេឌានបានទូលសុំព្រះជាម្ចាស់។
ទាល់តែគេឌានបានឃើញផ្ទាល់នឹងភ្នែកបែបនេះ ទើបជឿថាព្រះជាម្ចាស់ពិតជាគង់នៅជាមួយខ្លួនមែន ហើយគាត់ក៏បានពឹងផ្អែកលើព្រះជាម្ចាស់។
ព្រះជាម្ចាស់មានបន្ទូលបង្គាប់ឱ្យគេឌានជ្រើសរើសទ័ពទៅច្បាំងជាមួយនិងពួកម៉ាឌាន។
គេឌានបានធ្វើតាម ហើយចេញទៅកេណ្ឌទ័ពជាច្រើនដើម្បីចេញទៅច្បាំង។
នៅពេលនេះ ព្រះជាម្ចាស់មានបន្ទូលទៅគេឌានថា៖ «គេឌាន! ពួកទ័ពដែលនឹងចេញទៅច្បាំងមានគ្នាច្រើនពេកហើយ



ប្រសិនបើពួកឯងច្បាំងឈ្នះ នោះមនុស្សទាំងនោះ នឹងមានអំនួតលើខ្លួនឯង គិតថាពួកគេច្បាំងឈ្នះដោយកម្លាំង របស់ខ្លួនមិនមែនយើងជាអ្នកជួយជាមិនខាន។
ដូច្នេះ ចូរឯងកាត់បន្ថយចំនួនទ័ព ដោយទៅប្រាប់ពួកទាហានដែលមានចិត្តខ្លាចឱ្យពួកគេត្រឡប់ទៅផ្ទះវិញចុះ។
ក្រោយពីគេឌានបានយកតាមព្រះបន្ទូលព្រះជាម្ចាស់ទៅប្រាប់ពួកទាហានភ្លាម នោះមានទាហានចំនួនពីរពាន់នាក់ បានចាកចេញ នៅសល់តែមួយម៉ឺននាក់ប៉ុណ្ណោះ។
ព្រះជាម្ចាស់មានបន្ទូលមកទៀតថា៖
«កងទ័ពនៅតែមានចំនួនច្រើននៅឡើយ។ ចូរនាំពួកគេទៅមាត់ទឹក នោះយើងនឹងសាកល្បងពួកគេ»
គេឌានបាននាំពួកទាហានទៅមាត់ទឹកឱ្យពួកគេផឹកទឹកនៅទីនោះ។
ភ្លាមនោះ ព្រះជាម្ចាស់មានបន្ទូលឱ្យគេឌានរើសយកទាហានណាដែលយកដៃក្បង់ទឹកផឹក។
រហូតមកដល់ពេលនេះ ចំនួនទាហានគឺមាននៅសល់តែបីរយនាក់ទេ។
នៅយប់នោះ ព្រះជាម្ចាស់បានមានព្រះបន្ទូលទៅគេឌានថា៖ «ចូរងើបឡើងចេញទៅវាយជំរុំរបស់ពួកម៉ាឌានទៅ»
គេឌានបានឱ្យទាហានដៃម្ខាងកាន់ត្រែ ដៃម្ខាងទៀតកាន់ក្អមដែលមានចន្លុះ។
លុះជិតពាក់កណ្ដាលអធ្រាត្រ ពេលពួកទ័ពម៉ាឌានប្ដូរអ្នកយាម លោកគេឌាន និងទាហានបីរយនាក់បានផ្លុំត្រែឡើង  រួចបំបែកក្អមព្រមគ្នា។
បន្ទាប់មកពួកគេកាន់ចន្លុះនិងត្រែហើយស្រែកឡើងថា៖ «នេះជាដាវផងព្រះយេហូវ៉ា ហើយរបស់ផងគេឌានដែរ»
សម្លេងនោះបានធ្វើឱ្យពួកម៉ាឌានមានការភិតភ័យយ៉ាងខ្លាំង នាំគ្នាស្រែកឡើង ហើយចាប់ផ្ដើមកាប់សម្លាប់គ្នា។
គេឌាន បានទទួលជ័យជំនះលើសមរភូមិដោយព្រោះព្រះជាម្ចាស់បានជួយដល់ពួកគេ សម្លាប់ទាហានម៉ាឌានជា ច្រើន ដោយទាហានតែបីរយនាក់។



សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (ចៅហ្វាយ ៦៖១២)

«វិរជនដ៏អង់អាចអើយ ព្រះអម្ចាស់គង់នៅជាមួយអ្នកហើយ»។

## សកម្មភាពទី១ សូមភ្ជាប់ចំណុចដើម្បីបំពេញរូបភាព។



**សកម្មភាពទី២** សូមគិតអំពីខ្លឹមសារមេរៀនដែលរៀនបាននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។

